**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៤៩៥/០៩ **គ.ជ.ប**

**ជម្រាបជូន**
**លោក រស់ សួរ តំណាងគណបក្ស សម រង្ស៊ី**

**កម្មវត្ថុ** : ករណីប្តឹងជំទាស់មិនឲ្យឈ្មោះ មាស នៅ អតីតសមាជិកក្រុមប្រឹក្សាឃុំគគីធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ មកពីគណបក្ស សម រង្ស៊ី មានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឆ្នាំ២០០៩ ។

**យោង** : -ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ច.ប.ក)
-បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
-ពាក្យបណ្តឹងលេខ ០០៥/០៩ គ.ជ.ប ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩ របស់ឈ្មោះ រស់ សួរ
-អង្គប្រជុំ គ.ជ.ប ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩

តាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបលោកថា បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់លោកឲ្យមក គ.ជ.ប បានពិនិត្យពិចារណាយ៉ាងយកចិត្តទុកដាក់ឃើញថា អនុលោមតាមកថាខណ្ឌទី ២ មាត្រា ២៩ និង ៣៤ នៃ ច.ប.ក ហើយម្យ៉ាងទៀតការប្តឹងតវ៉ា ឬជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោត ត្រូវធ្វើក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។ ដូចនេះ គ.ជ.ប មិនអាចទទួលយកបណ្តឹងរបស់លោកមកដោះស្រាយបានឡើយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជ្រាប ។

សូមលោក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩
**គ.ជ.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការ**

**តេព នីថា**